អគ្គនាយកដ្ឋានពន្ធដារ

# ភារកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ ទាក់ទិននឹងការធ្វើសវនកម្ម




២០២២

## អារម្ភកថា

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តនាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៥ និងត្រូវបានអនុវត្តប្រកបដោយសមិទ្ធកម្មគួរជាទីមោទនៈ ដោយសម្រេចបានទាំងកំណើនចំណូល ការលើកកម្ពស់វប្បធម៌បង់ពន្ធរបស់ប្រជាពលរដ្ឋ និងការពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារបានរួមចំណែកយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចឱ្យបានយ៉ាងជោគជ័យ នូវគោលដៅយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដោយអគ្គនាយកដ្ឋានពន្ធដារបានសម្រេចនូវសមិទ្ធកម្មចម្បងៗមួយចំនួនដូចជា÷

- ការពង្រឹងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ
- ការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (Call center)
- ការដាក់ឱ្យប្រើប្រាស់វិក្កយបត្រតែមួយ (Single invoice) ការទូទាត់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-Payment) និងការទូទាត់ប្រាក់ពន្ធតាមប្រព័ន្ធធនាគារ
- ការដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យប្រមូលផ្តុំ (Centralized database)។

ជាលទ្ធផល ក្នុងរយៈពេល ៥ ឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធលើស

ផែនការប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំ និងសម្រេចបាននូវកំណើនចំណូលពន្ធ ក្នុងរង្វង់ប្រមាណ ២០% ក្នុងមួយឆ្នាំៗ ជាអាទិ៍ ឆ្នាំ២០១៤ បានចំនួន **៤ ២៦៧** ប៊ីលានរៀល **(១ ០៦៧** លានដុល្លារ) ឆ្នាំ២០១៥ បានចំនួន ៥ **២១០** ប៊ីលានរៀល (១ ៣០២ លានដុល្លារ) ឆ្នាំ២០១៦ បានចំនួន **៦** ០១០,៤៨ ប៊ីលានរៀល (១ ៥០២,៦២ លានដុល្លារ) ឆ្នាំ២០១៧ បានចំនួន **៧** ៩០៦,៥២ ប៊ីលានរៀល (១ ៩៧៦,៦៤ លានដុល្លារ) និងឆ្នាំ២០១៨ បានចំនួន ៨ **៧៩១**,៤០ ប៊ីលានរៀល (២ **១៩៧**,៨៥ លានដុល្លារ)។

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ឱ្យមានប្រសិទ្ធភាព។ ក្នុងនោះ អគ្គនាយកដ្ឋានពន្ធដារមានគោលបំណងក្នុងការផ្លាស់ប្តូរទៅជារដ្ឋបាលសារពើពន្ធ ដែលផ្តោតលើអ្នកជាប់ពន្ធ (Customer-oriented tax administration) តាមរយៈការពង្រឹងគុណភាពសេវា។ ក្នុងគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំនូវសៀវភៅណែនាំស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធទាក់ទិននឹងការធ្វើសវនកម្ម ដើម្បីជួយឱ្យអ្នកជាប់ពន្ធទាំងអស់យល់ដឹងកាន់តែច្បាស់បន្ថែមទៀតអំពីកាតព្វកិច្ច និងសិទ្ធិរបស់ខ្លួន។ ទន្ទឹមនេះ សៀវភៅនេះក៏ជាផែនទីចង្អុលផ្លូវសម្រាប់អគ្គនាយកដ្ឋានពន្ធដារក្នុងការបំពេញការងារសវនកម្ម ឱ្យមានតម្លាភាព និងប្រសិទ្ធភាព។

តាងនាមឱ្យអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសដែលបានចូលរួមសហការជាមួយអគ្គនាយកដ្ឋានពន្ធដារនាពេលកន្លងមក ដែលធ្វើឱ្យអគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់នឹងបន្តចូលរួមសហការ

ជាមួយអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលដៅជំរុញការអភិវឌ្ឍប្រទេសកម្ពុជា ដើម្បីប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ថ្ងៃសុក្រ ១៥ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មីនា ឆ្នាំ២០២២

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# មាតិកា


| បរិយាយ | ទំព័រ |
|---|---|
| សេចក្តីផ្តើម | ១ |
| ១. កាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធមុនពេលចុះធ្វើសវនកម្ម | ៤ |
| ២. កាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធអំឡុងពេលធ្វើសវនកម្ម | ១១ |
| ៣. កាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធក្រោយពេលធ្វើសវនកម្ម | ២១ |
| ចម្ងល់ផ្សេងៗ និងការពិគ្រោះយោបល់ | ២៦ |

# សេចក្តីផ្តើម

អនុលោមតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានកំណត់ទស្សនវិស័យ ក្នុងការប្រែក្លាយទៅជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់ពីគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីអនុវត្តទស្សនវិស័យនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវបេសកកម្មក្នុងការផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយសុចរិតភាពនិងស្មើភាព ចំពោះអ្នកជាប់ពន្ធទាំងអស់ ក្នុងគោលបំណងជំរុញអនុលោមភាពដោយស្ម័គ្រចិត្ត ឈានទៅសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការ និងយន្តការមួយចំនួន ក្នុងការពង្រឹងការអនុវត្តច្បាប់ និងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ដូចខាងក្រោម÷

- រៀបចំសិក្ខាសាលាជាប្រចាំជូនដល់អ្នកជាប់ពន្ធ
- ផ្តល់ការពិគ្រោះយោបល់ជាមួយអ្នកជាប់ពន្ធតាមរយៈ GDT Live Chat និង Call Center
- រៀបចំជាកម្មវិធីពន្ធដារកម្ពុជា និងរៀនអំពីពន្ធដារតាមអនឡាញ
- ផ្សព្វផ្សាយបទប្បញ្ញត្តិស្តីពីពន្ធដារតាមរយៈគេហទំព័រ និងហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ
- ដោះស្រាយរាល់បញ្ហាទាក់ទិននឹងបទប្បញ្ញត្តិ និងកាតព្វកិច្ចសារពើពន្ធរបស់វិស័យឯកជនតាមរយៈកិច្ចប្រជុំ វេទិកា និងការពិគ្រោះយោបល់ផ្សេងៗ។

ក្នុងនោះផងដែរ យន្តការមួយដ៏សំខាន់របស់អគ្គនាយកដ្ឋានពន្ធដារក្នុងការពង្រឹងការអនុវត្តច្បាប់ និងការផ្តល់សេវាដល់អ្នកជាប់ពន្ធ គឺការធ្វើសវនកម្មពន្ធដារ។ ការធ្វើសវនកម្មពន្ធដារគឺជាការពិនិត្យបញ្ជាក់លើបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធបានត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ ទន្ទឹមនឹងនេះ ការធ្វើសវនកម្មពន្ធដារក៏ផ្តល់ឱកាសឱ្យអគ្គនាយកដ្ឋានពន្ធដារផ្តល់សេវាអប់រំជូនអ្នកជាប់ពន្ធ តាមរយៈការពន្យល់ពីច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារនានា ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្ត និងស្ថានភាពជាក់ស្តែងរបស់សហគ្រាស។ បន្ថែមលើនេះ ការចុះផ្ទាល់របស់សវនករទៅដល់ទីតាំងសហគ្រាសអនុញ្ញាតឱ្យបណ្ណាធិការ ឬម្ចាស់សហ-គ្រាសបានយល់កាន់តែច្បាស់អំពីស្ថានភាពនៃការកាន់កាប់បញ្ជិកាគណនេយ្យ និងការបង់ពន្ធរបស់សហគ្រាស។

ក្នុងគោលដៅធានាតម្លាភាព និងសមធម៌ក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធក្នុងដំណើរការនៃការធ្វើសវនកម្មពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំជាសៀវភៅណែនាំស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធទាក់ទិននឹងការធ្វើសវនកម្ម។ តាមរយៈសៀវភៅនេះ អ្នកជាប់ពន្ធអាចយល់អំពីកាតព្វកិច្ច និងសិទ្ធិរបស់ខ្លួនមុនពេលចុះធ្វើសវនកម្ម អំឡុងពេលធ្វើសវនកម្ម និងក្រោយពេលធ្វើសវនកម្ម។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធទាក់ទិននឹងការធ្វើសវនកម្ម នឹងជួយលោក-លោកស្រីជាអភិបាលបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសឱ្យយល់កាន់តែច្បាស់ អំពីកាតព្វកិច្ច និងសិទ្ធិរបស់លោក-លោកស្រី ដើម្បីចូលរួមសហការជាមួយរដ្ឋបាលសារពើពន្ធក្នុងពេលធ្វើសវនកម្មឱ្យបានល្អប្រសើរ។

សវនកម្មពន្ធដារជាការពិនិត្យបញ្ជាក់លើបញ្ជិកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ[1]។ សវនកម្មពន្ធដារមានពីរប្រភេទគឺ សវនកម្មលើលិខិតស្នាម និងសវនកម្មដល់ទីកន្លែង។

**សវនកម្មលើលិខិតស្នាម** ធ្វើឡើងនៅទីកន្លែងរបស់រដ្ឋបាលសារពើពន្ធ និងត្រូវផ្ដោតការត្រួតពិនិត្យជាសំខាន់លើចំណុចមិនប្រក្រតីច្បាស់លាស់ និងងាយស្រួលដោះស្រាយ ដែលបានរកឃើញនៅក្នុងលិខិតប្រកាសសារពើពន្ធ ដូចជាការផ្ទៀងផ្ទាត់លិខិតប្រកាសពន្ធ ជាមួយនឹងព័ត៌មានដែលរដ្ឋបាលសារពើពន្ធទទួលបានពីប្រភពផ្សេងៗជាដើម។

**សវនកម្មដល់ទីកន្លែង** ជាការចុះត្រួតពិនិត្យដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាស ដើម្បីត្រួតពិនិត្យស្ថានភាពប្រតិបត្តិការអាជីវកម្មជាក់ស្ដែង បញ្ជីគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ។

ជាទូទៅ ចំពោះការធ្វើសវនកម្មលើលិខិតស្នាម អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យផ្ដល់ជាការពន្យល់ទៅលើចំណុចណាមួយជាក់លាក់ ដោយភ្ជាប់នូវឯកសារភ័ស្ដុតាង ក្នុងករណីចាំបាច់។ ដោយឡែក សម្រាប់ការធ្វើសវនកម្មដល់ទីកន្លែងដែលជាការត្រួតពិនិត្យមានលក្ខណៈស្មុគស្មាញ តម្រូវឱ្យមានការចូលរួម និងសហការឱ្យបានពេញលេញពីសំណាក់អ្នកជាប់ពន្ធ។ ដូចនេះ ការយល់ដឹងអំពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធទាក់ទិននឹងការធ្វើសវនកម្មជាការចាំបាច់ដើម្បីសម្រួលដល់កិច្ចដំណើរការសវនកម្មផង និងកាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធផង។

[1] ប្រកាសលេខ២៧០ សហវ.ប្រក ស្ដីពីសវនកម្មពន្ធដារ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩

សៀវភៅណែនាំស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធទាក់ទិននឹងការធ្វើសវនកម្ម នឹងពន្យល់អំពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ មុនពេលចុះធ្វើសវនកម្ម អំឡុងពេលធ្វើសវនកម្ម និងក្រោយពេលធ្វើសវនកម្ម។

## ១. ភាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធមុនពេលចុះធ្វើសវនកម្ម

មុនដំណើរការនៃការចុះធ្វើសវនកម្មដល់ទីកន្លែង សវនករពន្ធដារត្រូវជូនដំណឹងដល់អ្នកជាប់ពន្ធជាមុនអំពីការចុះត្រួតពិនិត្យនេះ តាមរយៈ**លិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ**។ លិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធជាលិខិតផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីផ្តល់សិទ្ធិជូនដល់សវនករពន្ធដារចុះធ្វើសវនកម្ម ហើយលិខិតនេះត្រូវប្រគល់តាមអាសយដ្ឋានសហគ្រាស ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ។

លិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ (ដូចមានក្នុងគំរូលិខិត (១)) មាននិទ្ទេសសំខាន់ៗជាអាទិ៍ ដូចខាងក្រោម÷

ក- ឈ្មោះអង្គភាពដែលទទួលបន្ទុកចុះធ្វើសវនកម្ម

ខ- ឈ្មោះសហគ្រាស និងលេខអត្តសញ្ញាណកម្មសារពើពន្ធ

គ- ឈ្មោះសវនករពន្ធដារ

ឃ- ប្រភេទសវនកម្ម

ង- កាលបរិច្ឆេទចេញលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ

ច- កាលបរិច្ឆេទដែលត្រូវចុះធ្វើសវនកម្ម

ឆ- ការិយបរិច្ឆេទដែលត្រូវរងសវនកម្ម

ជ- ត្រាសម្គាល់ផ្លូវការរបស់រដ្ឋបាលសារពើពន្ធ

ឈ- Barcode និង QR Code របស់អគ្គនាយកដ្ឋានពន្ធដារ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ក — នាយកដ្ឋានសវនកម្មសហគ្រាស

ង — រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០

**គំរូលិខិត (១)**

លេខ .......... អពដ.នសស

ជ — AU202003110188

**លិខិតជូនដំណឹង**
**ស្តីពី**
**ការចុះធ្វើសវនកម្មសារពើពន្ធ**

**គោរពជូន លោក-លោកស្រី នាយកក្រុមហ៊ុន**

ខ —
ឈ្មោះក្រុមហ៊ុន :
ជាអក្សរឡាតាំង :
លេខអត្តសញ្ញាណកម្ម :
សកម្មភាពអាជីវកម្ម :
អាសយដ្ឋាន :

ចុះបញ្ជីនៅ ៖សាខាពន្ធដារខេត្តសៀមរាប

ខ្ញុំមានកិត្តិយសសូមជម្រាបលោក-លោកស្រីនាយកក្រុមហ៊ុនថា អនុលោមតាមមាត្រា៩២ និងមាត្រា១០០ នៃច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានសវនកម្មសហគ្រាសបានចាត់សវនករពន្ធដារ ទៅកាន់សហគ្រាសលោក-លោកស្រី នៅ ច — [ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង១០:០០] ដើម្បីចុះធ្វើ ឃ — [សវនកម្មពេញលេញ] លើការប្រកាសសារពើពន្ធដែលទាក់ទិនពន្ធ-អាករគ្រប់ប្រភេទ ក្នុងការិយបរិច្ឆេទ ឆ — [០១-០១-២០១៦ ដល់ ៣១-១២-២០១៩]។

អាស្រ័យហេតុនេះ ខ្ញុំសូមស្នើឱ្យលោក-លោកស្រី មេត្តារៀបចំឯកសារគណនេយ្យ និងលិខិតមយុត្តិការនានា សម្រាប់ការធ្វើសវនកម្មដូចមានក្នុងតារាងជូនភ្ជាប់ជាមួយលិខិតនេះ។

ក្នុងករណីលោក-លោកស្រីមានការលំបាកក្នុងកិច្ចដំណើរការសវនកម្ម លោក-លោកស្រីអាចស្នើមក នាយកដ្ឋានសវនកម្មសហគ្រាស ដើម្បីពិនិត្យពិចារណា។

យោងតាមមាត្រា១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងរយៈពេលនៃការធ្វើសវនកម្ម លោក-លោកស្រីអាចជ្រើសរើសទីប្រឹក្សា ឬតំណាង ដើម្បីជួយដល់ការងារសវនកម្ម ដោយធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនមកនាយកដ្ឋានសវនកម្មសហគ្រាស។ ក្នុងករណីនេះ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់ទីប្រឹក្សា ឬតំណាង ដែលបានទទួលការផ្ទេរសិទ្ធិពីលោក-លោកស្រី។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស**

ឈ — P00000-2000-2000

គ — សវនករពន្ធដារ ៖

អគារលេខ មហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 715 ទូរសារ: (+855) 23 886 715, Email: dea@tax.gov.kh, Website: www.tax.gov.kh

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
ក នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
DEPARTMENT OF LARGE TAXPAYERS
លេខ.........................អពដ/ន/អធ
Nº GDT/LTD

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២០

គំរូលិខិត (១)

ជ AU202005120450

**លិខិតជូនដំណឹង**
**ស្តីពី**
**ការចុះធ្វើសវនកម្មសារពើពន្ធ**

**ជម្រាបជូន លោក-លោកស្រី នាយកក្រុមហ៊ុន**

ខ
ឈ្មោះក្រុមហ៊ុន :
ជាអក្សរឡាតាំង :
លេខអត្តសញ្ញាណកម្ម :
សកម្មភាពអាជីវកម្ម :
អាសយដ្ឋាន :

ចុះបញ្ជីនៅ :នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

---

ខ្ញុំមានកិត្តិយសសូមជម្រាបលោក-លោកស្រីនាយកក្រុមហ៊ុនថា អនុលោមតាមមាត្រា៩២ និងមាត្រា១០០ នៃច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំបានចាត់សវនករពន្ធដារ ទៅកាន់សហគ្រាសលោក-លោកស្រី នៅ ច ថ្ងៃទី 16 ខែមិថុនា ឆ្នាំ2020 វេលាម៉ោង 8:30 ដើម្បីចុះធ្វើ ឃ សវនកម្មមានកម្រិត លើការប្រកាសសារពើពន្ធដែលទាក់ទិនពន្ធ-អាករគ្រប់ប្រភេទ ក្នុងការិយបរិច្ឆេទ ឆ ០១-០១-២០១៩ ដល់ ៣០-០៤-២០២០ ។

អាស្រ័យហេតុនេះ ខ្ញុំសូមស្នើឱ្យលោក-លោកស្រី មេត្តារៀបចំឯកសារគណនេយ្យ និងលិខិតមយុត្តិការនានាសម្រាប់ការធ្វើសវនកម្មដូចមានក្នុងតារាងជូនភ្ជាប់ជាមួយលិខិតនេះ។

ក្នុងករណីលោក-លោកស្រីមានការលំបាកក្នុងកិច្ចដំណើរការសវនកម្ម លោក-លោកស្រីអាចស្នើមក នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដើម្បីពិនិត្យពិចារណា។

យោងតាមមាត្រា១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងរយៈពេលនៃការធ្វើសវនកម្ម លោក-លោកស្រីអាចជ្រើសរើសទីប្រឹក្សា ឬតំណាង ដើម្បីជួយដល់ការងារសវនកម្ម ដោយធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនមកនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។ ក្នុងករណីនេះ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់ទីប្រឹក្សា ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិពីលោក-លោកស្រី។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**

ឈ P00000-2000-2000

ឍ សវនករពន្ធដារ :

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 88 46 72 ទូរសារ: (+855) 23 886 700, Email: dlt@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ក សាខាពន្ធដារខណ្ឌចំការមន

លេខ ពដ.សខ.ចម

ង រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨

គំរូលិខិត (១)

## លិខិតជូនដំណឹង
## ស្តីពី
## ការចុះធ្វើសវនកម្មសារពើពន្ធ

**ជម្រាបជូន លោក-លោកស្រី នាយកក្រុមហ៊ុន**

ខ
ឈ្មោះក្រុមហ៊ុន ៖
ជាអក្សរឡាតាំង ៖
លេខអត្តសញ្ញាណកម្ម ៖ ចុះបញ្ជីនៅ ៖ សាខាពន្ធដារខណ្ឌចំការមន
អាសយដ្ឋាន ៖

ខ្ញុំមានកិត្តិយសសូមជម្រាបលោក-លោកស្រីនាយកក្រុមហ៊ុនថា អនុលោមតាមមាត្រា៩២ និងមាត្រា១០០ នៃច្បាប់ស្តីពីសារពើពន្ធ សាខាពន្ធដារខណ្ឌចំការមនបានចាត់សវនករពន្ធដារ ទៅកាន់សហគ្រាសលោក-លោកស្រី នៅថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១០:០០ ដើម្បីចុះធ្វើសវនកម្មលើលិខិតស្នាម លើការប្រកាសសារពើពន្ធដែលទាក់ទិនពន្ធ-អាករគ្រប់ប្រភេទ ក្នុងការិយបរិច្ឆេទ ០១-០១-២០១៧ ដល់ ៣១-១២-២០១៧។ (ច, ឃ, ឆ)

អាស្រ័យហេតុនេះ ខ្ញុំសូមស្នើឱ្យលោក-លោកស្រី មេត្តារៀបចំឯកសារគណនេយ្យ និងលិខិតមយុត្តិការនានា សម្រាប់ការធ្វើសវនកម្មដូចមានក្នុងតារាងជូនភ្ជាប់ជាមួយលិខិតនេះ។

ក្នុងករណីលោក-លោកស្រីមានការលំបាកក្នុងកិច្ចដំណើរការសវនកម្ម លោក-លោកស្រីអាចស្នើមក សាខាពន្ធដារខណ្ឌចំការមន ដើម្បីពិនិត្យពិចារណា។

យោងតាមមាត្រា១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងរយៈពេលនៃការធ្វើសវនកម្ម លោក-លោកស្រីអាចជ្រើសរើសទីប្រឹក្សា ឬតំណាង ដើម្បីជួយដល់ការងារសវនកម្ម ដោយធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនមកសាខាពន្ធដារខណ្ឌចំការមន។ ក្នុងករណីនេះ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់ទីប្រឹក្សា ឬតំណាង ដែលបានទទួលការផ្ទេរសិទ្ធិពីលោក-លោកស្រី។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**ប្រធានសាខាពន្ធដារខណ្ឌចំការមន**

ឈ
P00000-2000-2000

គ
សវនករពន្ធដារ ៖

អាគារលេខ ២៨ ផ្លូវលេខ ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855) 23 211 976, Email: chamkarmorn@tax.gov.kh, Website: www.tax.gov.kh

មុននឹងអនុញ្ញាតឱ្យសវនករពន្ធដារចុះត្រួតពិនិត្យ អ្នកជាប់ពន្ធមានសិទ្ធិពិនិត្យលើភាពត្រឹមត្រូវនៃលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ និងចំណុចសំខាន់ៗដូចមានរៀបរាប់ខាងលើ។ អ្នកជាប់ពន្ធត្រូវបានប្រគល់លិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធច្បាប់ដើមមួយច្បាប់ និងត្រូវចុះហត្ថលេខាទទួលលើលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធសម្រាប់សវនករពន្ធដារមួយច្បាប់។ ក្នុងករណីអ្នកជាប់ពន្ធពុំព្រមទទួលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ ឬបង្កការលំបាកក្នុងការប្រគល់/ទទួលលិខិតនេះ សវនករពន្ធដារមានសិទ្ធិផ្ញើលិខិតជូនដំណឹងនេះ តាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋ ឬបិទលិខិតជូនដំណឹងនោះភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬផ្សព្វផ្សាយតាមសារព័ត៌មានដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឱ្យលើសពី ១៥ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។ លិខិតជូនដំណឹងដែលបានអនុវត្តតាមមធ្យោបាយទាំងនេះមានតម្លៃស្មើនឹងអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងដោយផ្ទាល់។ ក្នុងករណីដែលអ្នកជាប់ពន្ធបានផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម ហើយមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធ លិខិតជូនដំណឹងដែលបានបញ្ជូនទៅអាសយដ្ឋាន ដែលអ្នកជាប់ពន្ធបានប្រកាសចុងក្រោយមករដ្ឋបាលសារពើពន្ធ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ។

ភ្ជាប់ជាមួយលិខិតជូនដំណឹងនេះ អ្នកជាប់ពន្ធនឹងទទួលបានបញ្ជីស្នើសុំឯកសារ និងព័ត៌មានបឋម ដែលសវនករពន្ធដារស្នើឱ្យអ្នកជាប់ពន្ធផ្តល់ និងត្រៀមរៀបចំឱ្យបានរួចជាស្រេច ក្នុងអំឡុងពេលសវនករពន្ធដារចុះត្រួតពិនិត្យដល់ទីកន្លែង។ អ្នកជាប់ពន្ធមានកាតព្វកិច្ចរៀបចំឯកសារតាមការស្នើសុំរបស់សវនករពន្ធដារ ទៅតាមស្ថានភាពជាក់ស្តែងរបស់សហគ្រាស ជាអាទិ៍មាន÷

១- ព័ត៌មានសហគ្រាស÷

- រចនាសម្ព័ន្ធគ្រប់គ្រង

- វិញ្ញាបនបត្រចុះបញ្ជី
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- លក្ខន្តិកៈ
- វិញ្ញាបនបត្រផ្សេងៗ សម្រាប់ធ្វើសកម្មភាពអាជីវកម្មពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទេសចរណ៍ ជាដើម។ល។

២- ឯកសារគណនេយ្យ÷

- របាយការណ៍ហិរញ្ញវត្ថុ
- តារាងលម្អិតគណនីនីមួយៗនៃទ្រព្យសកម្ម
- តារាងលម្អិតគណនីនីមួយៗនៃទុនម្ចាស់ទ្រព្យនិងបំណុល
- តារាងលម្អិតគណនីនីមួយៗនៃរបាយការណ៍លទ្ធផល (ចំណេញ/ខាត)
- សក្ខីបត្រដើមនៃឯកសារផ្សេងៗ÷
    - តារាងបើកប្រាក់បៀវត្សប្រចាំខែ
    - កិច្ចសន្យាការងាររបស់បុគ្គលិកបរទេសនិងថ្នាក់គ្រប់គ្រង
    - កិច្ចសន្យាជួលឬលក់ផ្សេងៗ
    - កិច្ចសន្យាដេញថ្លៃផ្សេងៗ បើមាន
    - លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ
    - ទិនានុប្បវត្តិទិញ-លក់ប្រចាំខែ
    - តារាងកែតម្រូវការគណនាប្រាក់ពន្ធ
    - វិក្កយបត្រទិញ-លក់។ល។

ក្រោយទទួលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ និងរៀបចំឯកសារតាមការតម្រូវរបស់សវនករពន្ធដារ អ្នកជាប់ពន្ធត្រូវត្រៀមចាត់ចែងសម្រួលដល់

សវនករពន្ធដារនៅពេលចុះត្រួតពិនិត្យទៅតាមពេលវេលា និងទីកន្លែងដែលបានកំណត់។ យោងតាមច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវកត់ត្រា កាន់កាប់ រក្សាទុកបញ្ជិកាគណនេយ្យ និងឯកសារគាំទ្រទាំងនេះរយៈពេល ១០ឆ្នាំ[2]។

ជាទូទៅ ការចុះធ្វើសវនកម្មចាប់ផ្តើមដំណើរការចាប់ពីរយៈពេល ១០ថ្ងៃ ក្រោយថ្ងៃជូនដំណឹងស្តីពីការធ្វើសវនកម្ម។ ប្រសិនបើអ្នកជាប់ពន្ធមិនអាចរៀបចំឯកសារ និងសម្រួលដល់សវនករពន្ធដារក្នុងការចុះត្រួតពិនិត្យតាមពេលវេលាកំណត់បានទេ អ្នកជាប់ពន្ធអាចស្នើសុំពន្យារពេលចុះធ្វើសវនកម្ម ដោយផ្អែកលើមូលហេតុសមស្រប ដោយមិនឱ្យលើសពី ៣០ថ្ងៃ ក្រោយថ្ងៃត្រូវចុះធ្វើសវនកម្ម។ ក្នុងករណីរយៈពេលស្នើសុំតិចជាង ១០ថ្ងៃ អ្នកជាប់ពន្ធអាចធ្វើការស្នើសុំដោយផ្ទាល់មាត់មកសវនករពន្ធដារ។ ក្នុងករណីរយៈពេលស្នើសុំចាប់ពី ១០ថ្ងៃ ដល់ ៣០ថ្ងៃ អ្នកជាប់ពន្ធត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអង្គភាពដែលទទួលបន្ទុកការធ្វើសវនកម្មនោះ[3]។

[2] មាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ

[3] ប្រកាសលេខ២៧០ សហវ.ប្រក ស្តីពីសវនកម្មពន្ធដារ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩

## ២. ភារកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធអំឡុងពេលធ្វើសវនកម្ម

ដល់ថ្ងៃកំណត់ ដូចមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ សវនករពន្ធដារនឹងចុះត្រួតពិនិត្យដល់ទីតាំងសហគ្រាសតាមអាសយដ្ឋានដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ ហើយអ្នកជាប់ពន្ធត្រូវបង្ហាញខ្លួនតាមកាលបរិច្ឆេទ និងទីកន្លែងដែលមានបញ្ជាក់ក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើ-ពន្ធ។ ជាទូទៅ ពេលវេលានៃការណាត់ជួបនៅទីតាំងសហគ្រាសអាចប្រែប្រួល អាស្រ័យលើការពិភាក្សារវាងសវនករពន្ធដារ និងអ្នកជាប់ពន្ធ។

នៅពេលចុះដល់ទីតាំងរបស់សហគ្រាស សវនករពន្ធដារត្រូវប្រើប្រាស់ឯកសណ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវលិខិតឧទ្ទេសនាម ចេញដោយអគ្គនាយកដ្ឋានពន្ធដារ (ដូចមានក្នុងគំរូលិខិត (២))។ លិខិតឧទ្ទេសនាមមាននិទ្ទេស ដូចខាងក្រោម÷

ក- ឈ្មោះ និងតួនាទីរបស់សវនករពន្ធដារ

ខ- ឈ្មោះ និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាសដែលត្រូវទទួលរងការធ្វើសវនកម្ម

គ- កាលបរិច្ឆេទត្រូវចុះធ្វើសវនកម្ម

ឃ- Barcode QR Code និងត្រាសម្គាល់របស់រដ្ឋបាលសារពើពន្ធ។

ខណៈពេលដែលសវនករពន្ធដារបង្ហាញលិខិតឧទ្ទេសនាម អ្នកជាប់ពន្ធមានសិទ្ធិត្រួតពិនិត្យលិខិតឧទ្ទេសនាម និងលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ និងអាចធ្វើការផ្ទៀងផ្ទាត់ QR Code តាមរយៈកម្មវិធីត្រួតពិនិត្យ និងតាមដានឯកសាររបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ មុនពេលអនុញ្ញាតឱ្យសវនករពន្ធដារចូលបំពេញការងារនៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលបានចាត់ទុកជាគ្រឹះស្ថានអាជីវកម្ម ឬកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀត នៅក្នុងពេល

ប្រកបអាជីវកម្ម។ ប៉ុន្តែ អ្នកជាប់ពន្ធត្រូវរាយការណ៍មកអគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីពិនិត្យលិខិតឧទ្ទេសនាមឃើញថាមានភាពមិនប្រក្រតី។

នៅក្នុងដំណាក់កាលនេះ អ្នកជាប់ពន្ធត្រូវប្រគល់ឯកសារពាក់ព័ន្ធនឹងអាជីវកម្មដែលបានស្នើសុំ ជូនសវនករពន្ធដារដើម្បីត្រួតពិនិត្យ។ ប្រសិនបើឯកសារ និងបញ្ជិកាគណនេយ្យបានរក្សាទុកជាទម្រង់អេឡិចត្រូនិក អ្នកជាប់ពន្ធត្រូវមានឯកសារច្បាប់ដើមជាក្រដាសស្នាមសម្រាប់ការត្រួតពិនិត្យ។ ប៉ុន្តែប្រសិនបើមិនមានឯកសារជាក្រដាសស្នាមទេ អ្នកជាប់ពន្ធត្រូវអនុញ្ញាតនិងរៀបចំឱ្យសវនករពន្ធដារអាចត្រួតពិនិត្យប្រព័ន្ធកុំព្យូទ័រ និងថតចម្លងឯកសារជាទម្រង់អេឡិចត្រូនិក តាមរយៈឧបករណ៍ថតចម្លង។ ក្នុងករណីទីតាំងការងារដែលផ្តល់ដោយអ្នកជាប់ពន្ធមិនសមស្របសម្រាប់បំពេញការងារសវនកម្ម ឬគ្មានម៉ាស៊ីនថតចម្លង អ្នកជាប់ពន្ធត្រូវប្រគល់ឯកសារទាំងនោះឱ្យសវនករពន្ធដារយកទៅពិនិត្យនៅការិយាល័យរដ្ឋបាលសារពើពន្ធ។ នៅពេលប្រគល់ឯកសារដល់សវនករពន្ធ-ដារដើម្បីត្រួតពិនិត្យ អ្នកជាប់ពន្ធមានសិទ្ធិទទួលបានលិខិតប្រគល់-ទទួលឯកសារជាលាយលក្ខណ៍អក្សរ ដែលមានហត្ថលេខាទទួលពីសវនករពន្ធដារ។ ប្រសិនបើឯកសារ និងលិខិតពាក់ព័ន្ធផ្សេងៗដែលចាំបាច់សម្រាប់ការងារសវនកម្មជាភាសាបរទេស អ្នកជាប់ពន្ធត្រូវបកប្រែជាភាសាខ្មែរទៅតាមការតម្រូវរបស់សវនករពន្ធដារ។

ក្រៅពីការពិនិត្យឯកសារ និងបញ្ជិកាគណនេយ្យ សវនករពន្ធដារមានសិទ្ធិធ្វើការសម្ភាសជាមួយប្រធានក្រុមហ៊ុន ប្រធានផ្នែក (បុគ្គលិក ហិរញ្ញវត្ថុ ទីផ្សារ...) ឬបុគ្គលិកណាមួយដែលចាំបាច់ក្នុងការផ្តល់ព័ត៌មានទាក់ទិននឹងការងារសវនកម្ម។ អ្នកជាប់ពន្ធមានកាតព្វកិច្ចផ្តល់ព័ត៌មានដែលពិតប្រាកដ និងលម្អិតអំពីប្រតិបត្តិការអាជីវកម្មរបស់សហ-គ្រាស រួមទាំងព័ត៌មានផ្សេងៗទៀតដែលទាក់ទិននឹងដំណើរការនៃការធ្វើសវនកម្ម។

ក្នុងករណីដែលអ្នកជាប់ពន្ធមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធសម្ភាស ឬពិនិត្យបញ្ជិកាគណនេយ្យ ឬឯកសារផ្សេងៗ ឬព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថាប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពី

ពន្ធដារ ហើយត្រូវទទួលរងពិន័យជាប្រាក់ពី ៥លាន ទៅ ១០លានរៀល ឬ/និងជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ[4]។

អ្នកជាប់ពន្ធមានសិទ្ធិទទួលបានការរក្សាការសម្ងាត់នូវរាល់ព័ត៌មាននានា ទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួន ដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេលធ្វើសវនកម្មនេះ។

នៅក្នុងដំណើរការនៃការចុះត្រួតពិនិត្យដល់ទីកន្លែងនេះ សវនករពន្ធដារនឹងបំពេញការងារនៅទីតាំងរបស់សហគ្រាស ដើម្បីត្រួតពិនិត្យ ឈ្វេងយល់ និងផ្ទៀងផ្ទាត់ឯកសារ ក៏ដូចជាប្រមូលព័ត៌មានដែលចាំបាច់នានាពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធ។ ជាទូទៅ រយៈពេលនៃការចុះត្រួតពិនិត្យដល់ទីតាំងសហ-គ្រាសអាចប្រើប្រាស់ពេលវេលាពី ២ ទៅ ៣ ថ្ងៃ ឬយូរជាងនេះ អាស្រ័យលើកត្តាមួយចំនួន ដូចខាងក្រោម÷

ក- ការសហការរបស់អ្នកជាប់ពន្ធ (ការផ្តល់ឯកសារ ការពន្យល់បំភ្លឺ ។ល។)

ខ- ទំហំប្រតិបត្តិការអាជីវកម្ម

គ- ភាពស្មុគស្មាញនៃប្រតិបត្តិការអាជីវកម្ម

ឃ- កម្រិតហានិភ័យរបស់អ្នកជាប់ពន្ធ ។ល។

ការចុះត្រួតពិនិត្យដល់ទីតាំងរបស់សហគ្រាសអាចត្រូវបានធ្វើឡើងមួយលើក ឬច្រើនលើក ប្រសិនបើសវនករពិនិត្យឃើញថាមានការចាំបាច់ក្នុងការចុះដល់ទីតាំងអាជីវ-កម្មរបស់អ្នកជាប់ពន្ធ។ ទន្ទឹមនោះ រាល់ការចុះធ្វើសវនកម្មមួយលើកៗ សវនករអាចធ្វើការស្នើសុំឯកសារបន្ថែម ហើយអ្នកជាប់ពន្ធត្រូវផ្តល់ឯកសារដែលបានស្នើសុំយ៉ាងយឺតបំផុត ៧ ថ្ងៃក្រោយការស្នើសុំ។

[4] មាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ

ក្នុងដំណាក់កាលនេះ អ្នកជាប់ពន្ធមានសិទ្ធិជ្រើសរើសតំណាងស្របច្បាប់ ដោយមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរជូនរដ្ឋបាលសារពើពន្ធ ហើយអ្នកជាប់ពន្ធមានកាតព្វកិច្ចទទួលខុសត្រូវដោយផ្ទាល់ ចំពោះរាល់សកម្មភាពរបស់បុគ្គលជាតំណាងស្របច្បាប់ ដែលបានទទួលការផ្ទេរសិទ្ធិរហូតដល់ពេលបញ្ចប់ការធ្វើសវនកម្ម ឬពេលណាមួយដែលរដ្ឋបាលសារពើពន្ធទទួលបានសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធស្តីអំពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ។

បន្ទាប់ពីការពិនិត្យឯកសារ បញ្ជិកាគណនេយ្យ និងសម្ភាសជាមួយអ្នកជាប់ពន្ធ សវនករពន្ធដារត្រូវធ្វើកំណត់ហេតុសវនកម្ម ដោយមានចុះហត្ថលេខាអ្នកជាប់ពន្ធឬតំណាងស្របច្បាប់ និងត្រូវបោះត្រារបស់សហគ្រាសលើកំណត់ហេតុសវនកម្ម។ កំណត់ហេតុសវនកម្មត្រូវធ្វើឡើងជាពីរច្បាប់ មួយច្បាប់ប្រគល់ជូនអ្នកជាប់ពន្ធឬតំណាងស្របច្បាប់ និងមួយច្បាប់ទៀតសម្រាប់សវនករពន្ធដារ។

បន្ទាប់ពីការចុះពិនិត្យដល់ទីតាំងសហគ្រាស អ្នកជាប់ពន្ធអាចនឹងត្រូវបានអញ្ជើញដោយផ្ទាល់មាត់ ឬតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ (ដូចមានក្នុងគំរូលិខិត (៣)) ដើម្បីផ្តល់ព័ត៌មាន ឬឯកសារបន្ថែម ឬបំភ្លឺលើចំណុចមិនច្បាស់លាស់មួយចំនួននៅទីកន្លែងរបស់រដ្ឋបាលសារពើពន្ធ។ អ្នកជាប់ពន្ធត្រូវបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធ និងត្រូវផ្តល់ឯកសារដែលបានស្នើសុំយ៉ាងយឺតបំផុតក្នុងរយៈពេល ៧ថ្ងៃ (ដូចមានក្នុងគំរូលិខិត (៤))។

នៅក្នុងដំណើរការនៃការធ្វើសវនកម្ម អ្នកជាប់ពន្ធមានសិទ្ធិទទួលបានព័ត៌មានទាំងឡាយអំពីកិច្ចដំណើរការសវនកម្ម រួមទាំងការផ្តល់សេវាអប់រំអំពីកាតព្វកិច្ចនិងសិទ្ធិច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងការកាន់កាប់បញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ។

មុនបញ្ចប់ដំណើរការសវនកម្ម សវនករពន្ធដារត្រូវធ្វើការបូកសរុបលទ្ធផលសវនកម្ម និងត្រូវពន្យល់អ្នកជាប់ពន្ធអំពីភាពត្រឹមត្រូវឬមិនត្រឹមត្រូវនៃការប្រកាសបង់ពន្ធ

របស់អ្នកជាប់ពន្ធ។ អ្នកជាប់ពន្ធត្រូវបានផ្តល់ព័ត៌មានអំពីលទ្ធផលចុងក្រោយនៃការធ្វើសវនកម្ម ដោយក្នុងនោះលទ្ធផលអាចមានការកំណត់ពន្ធឡើងវិញ ឬគ្មានការកំណត់ពន្ធឡើងវិញ។

ក្នុងករណីមានការកំណត់ពន្ធឡើងវិញ សវនករពន្ធដារត្រូវពន្យល់អ្នកជាប់ពន្ធអំពី÷

- ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារដែលបានរកឃើញ
- មូលដ្ឋាននិងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធដែលទាក់ទិននឹងការកំណត់ពន្ធ
- ប្រាក់ពន្ធដែលនឹងត្រូវកំណត់ឡើងវិញ។

ក្នុងដំណាក់កាលនេះ អ្នកជាប់ពន្ធមានសិទ្ធិក្នុងការយល់ស្រប ឬជំទាស់នូវចំណែកណាមួយឬទាំងស្រុងនៃលទ្ធផលសវនកម្ម ដោយត្រូវបង្ហាញឯកសារបន្ថែមដែលគាំទ្រដល់ការជំទាស់របស់ខ្លួន។ ក្នុងការបិទបញ្ចប់ការងារសវនកម្ម សវនករពន្ធដារនឹងធ្វើកំណត់ហេតុសវនកម្មចុងក្រោយជាមួយអ្នកជាប់ពន្ធផ្ទាល់ ឬតំណាងស្របច្បាប់ ទោះបីជាអ្នកជាប់ពន្ធឯកភាព ឬមិនឯកភាពចំពោះលទ្ធផលនៃការធ្វើសវនកម្មក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ........................អពដ

គំរូលិខិត (២)

**លិខិតឧទ្ទេសនាម**

**អគ្គនាយកដ្ឋានពន្ធដារ សូមឧទ្ទេសនាម**

| | | |
|---|---|---|
| លោកស្រី | : | អត្តលេខ : |
| ឋានៈ | : អនុប្រធានការិយាល័យរៀបចំថ្លៃទុកជាមុន និងការផ្ទេរថ្លៃ | |
| លោក | : | អត្តលេខ : |
| ឋានៈ | : មន្ត្រីការិយាល័យរៀបចំថ្លៃទុកជាមុន និងការផ្ទេរថ្លៃ | |
| ធ្វើការនៅ | : នាយកដ្ឋានសវនកម្មសហគ្រាស | |
| មានភារកិច្ច | : ចុះធ្វើសវនកម្មពេញលេញ | |
| ឈ្មោះជាខ្មែរ | : | |
| ឈ្មោះជាឡាតាំង | : | |
| លេខអតប | : | |
| ស្ថិតនៅក្រោម | : នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | |
|ការិយបរិច្ឆេទ | : ០១-០១-២០១៩ ដល់ ៣១-១២-២០២០ | |

អាស្រ័យហេតុនេះ សូមក្រសួង មន្ទីរ ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ជួយសម្រួលដល់មន្ត្រីខាងលើ ឱ្យអនុវត្តការងារបានសំរេចជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២១

P00000-2000-2000

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ទីប្រឹក្សារាជរដ្ឋាភិបាល**
**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង វិថីសេចុង (២៨៩) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានសវនកម្មសហគ្រាស
លេខ. អពដ.នសស

L20000101001 | TD0001

ថ្ងៃ.................. ខែ.................. ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩

**គំរូលិខិត (៣)**

**ជម្រាបជូន**
**លោក-លោកស្រីនាយក**

ឈ្មោះក្រុមហ៊ុន ÷
ជាអក្សរឡាតាំង ÷
លេខអត្តសញ្ញាណកម្ម ÷
អាសយដ្ឋាន ÷

ចុះបញ្ជីនៅ ÷ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

**កម្មវត្ថុ** ÷ ស្តីពីការអញ្ជើញចូលរួមពិភាក្សាលើបញ្ហាមួយចំនួន ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសរបស់លោក-លោកស្រី ជាមួយនាយកដ្ឋានសវនកម្មសហគ្រាស

**យោង** ÷ លិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធលេខ អពដ.នសស របស់នាយកដ្ឋានសវនកម្មសហគ្រាស ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក-លោកស្រីនាយកក្រុមហ៊ុនជ្រាបថា: នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ សូមអញ្ជើញលោក-លោកស្រីនាយកក្រុមហ៊ុន ឬតំណាងក្រុមហ៊ុនដែលមានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរមកចូលរួម ដើម្បីផ្តល់កិច្ចសហការក្នុងការពិភាក្សាលើបញ្ហាមួយចំនួន ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចសារពើពន្ធរបស់ក្រុមហ៊ុន
ជាមួយនាយកដ្ឋានសវនកម្មសហគ្រាស តាមពេលវេលា និងទីកន្លែង ដូចខាងក្រោម÷

- កាលបរិច្ឆេទ :
- វេលាម៉ោង :
- ទីកន្លែង :

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីនាយកក្រុមហ៊ុន មេត្តាចូលរួមកុំបីអាក់ខាន។

សូមលោក-លោកស្រីនាយកទទួលនូវការរាប់អានពីខ្ញុំ

**ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស**

**ចម្លងជូន ÷**
- ឯកសារ-កាលប្បវត្តិ

**សវនករ÷**
**លេខទំនាក់ទំនង÷**

អគារលេខបហារីថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៨៩) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 715, ទូរសារ: (+855) 23 886 715, Email: dea@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានសវនកម្មសហគ្រាស
លេខ          អពដ.នសស

L20000101001 | TD0001

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៩

**គំរូលិខិត (៤)**

**ជម្រាបជូន**
**លោក-លោកស្រីនាយក**

ឈ្មោះក្រុមហ៊ុន ÷
ជាអក្សរឡាតាំង ÷
លេខអត្តសញ្ញាណកម្ម ÷
អាសយដ្ឋាន ÷

ចុះបញ្ជីនៅ ÷ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

**កម្មវត្ថុ** ÷ ការផ្តល់បញ្ជិកាគណនេយ្យ លិខិតយុត្តិកា និងឯកសារពាក់ព័ន្ធផ្សេងៗចំពោះការធ្វើសវនកម្មសហគ្រាស សម្រាប់ការិយបរិច្ឆេទ ២០១៦ និង ២០១៧

**យោង** ÷ - ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣
- លិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធលេខ អពដ.នសស ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ របស់នាយកដ្ឋានសវនកម្មសហគ្រាស

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក-លោកស្រីនាយកជ្រាបថា÷ តាមលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មសារពើពន្ធលេខ អពដ.នសស ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ នាយកដ្ឋានសវនកម្មសហគ្រាសបានចាត់សវនករពន្ធដារដើម្បីចុះធ្វើសវនកម្មពេញលេញលើការប្រកាសពន្ធដែលទាក់ទិនពន្ធ-អាករគ្រប់ប្រភេទ ក្នុងការិយបរិច្ឆេទ ២០១៦ និង ២០១៧។ ប៉ុន្តែរហូតមកដល់ពេលនេះសហគ្រាសរបស់លោក-លោកស្រី នៅពុំទាន់បានផ្តល់បញ្ជិកាគណនេយ្យ លិខិតយុត្តិកា និងឯកសារពាក់ព័ន្ធផ្សេងៗទៀតដូចជា÷ លក្ខន្តិកៈក្រុមហ៊ុន ប័ណ្ណប៉ាតង់ កិច្ចសន្យាជួលទីតាំង តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍ចលនាសាច់ប្រាក់ តារាងតុល្យភាព សៀវភៅធំ របាយការណ៍ធនាគារប្រចាំខែ លិខិតប្រកាសសារពើពន្ធប្រចាំខែ លិខិតប្រកាសពន្ធប្រចាំឆ្នាំ តារាងបើកប្រាក់បៀវត្សប្រចាំខែ តារាងបញ្ជីទ្រព្យសកម្មរយៈពេលវែង កិច្ចសន្យាទិញ-លក់ កិច្ចសន្យាខ្ចីប្រាក់ និងវិក្កយបត្រទិញ-លក់ ។

ការមិនបានផ្តល់នូវឯកសារទាំងនេះ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តិអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ១២៨ មាត្រា ១៣៣ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

រដ្ឋបាលសារពើពន្ធមានសមត្ថកិច្ចក្នុងការទទួលព័ត៌មាន ដូចមានចែងក្នុងមាត្រា ៩២ និង៩៩ នៃច្បាប់ស្តីពីសារពើពន្ធដែលបានចែងថា÷

***មាត្រា ៩២. អំណាច និងភារកិច្ចរបស់រដ្ឋបាលសារពើពន្ធ***

*អំណាចរបស់រដ្ឋបាលសារពើពន្ធមានដូចខាងក្រោមនេះ÷*

*៣.កំណត់បញ្ជី ឯកសារចាំបាច់នានា និងលិខិតយុត្តិកា ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ៩៨ និងមាត្រា ១០០ នៃច្បាប់នេះ។*

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង វ៉ែកសេវ៉ុង (២៨៩) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 715, ទូរសារ: (+855) 23 886 715, Email: dea@tax.gov.kh, Website: www.tax.gov.kh

គំរូលិខិត (៤)

L20000101001 | TD0001

*៤. ទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជនផ្ដល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុង មាត្រា៩៩ នៃច្បាប់នេះ។*

*៥. ចូលលំនៅដ្ឋាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជនដើម្បីទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១០០ នៃច្បាប់នេះ។*

*៦. ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្ដីពី ឬដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១១៦ នៃច្បាប់នេះ។*

***មាត្រា៩៩. សិទ្ធិទទួលព័ត៌មាន***

*ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជនឱ្យ÷*

*- ផ្ដល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្ដីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ។*

*- បង្ហាញខ្លួនទៅតាមពេលវេលានិងទីកន្លែង ដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ដើម្បីផ្ដល់ព័ត៌មាន និងដើម្បីបង្ហាញ ឬផ្ដល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។*

*-ម្យ៉ាងទៀតផ្អែកតាមមាត្រា ៩៤ នៃច្បាប់ស្ដីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធក៏មានក្រមសីលធម៌រក្សាទុកការសំងាត់នូវព័ត៌មានដែលទាក់ទងនឹងអ្នកជាប់ពន្ធ ដែលបានទទួលនៅក្នុងពេលបំពេញភារកិច្ចផ្លូវការដែរ។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយកផ្ដល់ឯកសារ លិខិតស្នាមយុត្តិកា និងបញ្ជិកាគណនេយ្យ ផ្សេងៗទៀត តាមការស្នើសុំដល់មន្ត្រីពន្ធដារមានសមត្ថកិច្ច ដូចមានចែងក្នុងច្បាប់ស្ដីពីសារពើពន្ធ ដើម្បីបំពេញការងារសវនកម្មឱ្យចប់រួចរាល់។ **សូម លោក-លោកស្រីនាយក ឆ្លើយតបជាលាយលក្ខអក្សរចំពោះឯកសារដែលក្រុមហ៊ុនអាចផ្ដល់ឱ្យមន្ត្រីមានសមត្ថកិច្ច និងឯកសារដែលក្រុមហ៊ុនគ្មានមិនអាចផ្ដល់អោយបានយ៉ាងយូរបំផុតត្រឹម ៧ ថ្ងៃក្រោយទទួលលិខិតនេះជាកំហិត។** ក្នុងករណីរាំងស្ទះដល់ការអនុវត្តន៍បទបញ្ញត្តិស្ដីពីពន្ធដារ ក្រុមហ៊ុនលោក-លោកស្រី នឹងត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគី ឬទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ ១៣៥ និង ១៣៦។

សូមលោក-លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស**

ចម្លងជូន ÷

- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
DEPARTMENT OF LARGE TAXPAYERS
លេខ..........................អពធ/ន/អធ
Nº GDT/LTD

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

L20000101001 | TD0001

ថ្ងៃ សុក្រ. ៦ កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក-លោកស្រីនាយក**

គំរូលិខិត (៤)

ឈ្មោះក្រុមហ៊ុន ÷
ជាអក្សរឡាតាំង ÷
លេខអត្តសញ្ញាណកម្ម ÷ ចុះបញ្ជីនៅ ÷ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អាសយដ្ឋាន ÷

**កម្មវត្ថុ** ÷ ស្តីពីការផ្តល់ឯកសារទាក់ទិននឹងការធ្វើសវនកម្មមានកម្រិត

**យោង** ÷ លិខិតលេខ អពធ/ន/អធ ស្តីពីការជូនដំណឹងស្តីពីការធ្វើសវនកម្មសារពើពន្ធ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ របស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំសូមជម្រាបជូនលោក-លោកស្រីនាយកក្រុមហ៊ុន ជ្រាបថា កន្លងមកនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំពិនិត្យឃើញថា ក្រុមហ៊ុនលោក-លោកស្រី ពុំបានសហការពេញលេញ និងបង្កលក្ខណៈងាយស្រួលដល់សវនករបំពេញការងារសវនកម្ម ដូច្នេះនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តម្រូវឱ្យក្រុមហ៊ុនលោក-លោកស្រីផ្តល់ឯកសារចាំបាច់មួយចំនួនដូចជា÷

- ឯកសារសក្ខីបត្រដើមគណនេយ្យ
- កិច្ចសន្យាសាងសង់ និងកិច្ចសន្យាការងារនិយោជិតបរទេស
- របាយការណ៍ធនាគារ ពីខែមករា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំសង្ឃឹមថាលោក-លោកស្រី នឹងផ្តល់កិច្ចសហការបានល្អប្រសើរតាមការតម្រូវរបស់នាយកដ្ឋាន ដោយផ្តល់នូវឯកសារទាំងនោះមកកាន់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំយ៉ាងយូរត្រឹម ០៧ ថ្ងៃក្រោយពីបានទទួលលិខិតនេះ។ ក្នុងករណីក្រុមហ៊ុនលោក-លោកស្រីពុំបានផ្តល់ឯកសារតាមការតម្រូវទេ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនឹងធ្វើការកំណត់ពន្ធឡើងវិញជាឯកតោភាគី ដោយផ្អែកតាមព័ត៌មានដែលនាយកដ្ឋានមាន។

សូមលោក-លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

**ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 88 46 72 ទូរសារ: (+855) 23 886 700, Email: dlt@tax.gov.kh, Website: www.tax.gov.kh

## ៣. ភាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធក្រោយពេលធ្វើសវនកម្ម

ក្រោយការធ្វើសវនកម្មត្រូវបានបញ្ចប់ រដ្ឋបាលសារពើពន្ធត្រូវជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ÷

- ករណីដែលលទ្ធផលនៃការធ្វើសវនកម្ម មិនតម្រូវឱ្យមានការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធនឹងទទួលបានលិខិតជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញដែលគ្មានទឹកប្រាក់ពន្ធ (ដូចមានក្នុងគំរូលិខិត (៥))។
- ករណីមានទឹកប្រាក់ពន្ធកំណត់ឡើងវិញ ឬមានការកែប្រែទិន្នន័យដែលជាមូលដ្ឋានក្នុងការគណនាប្រាក់ពន្ធ-អាករ អ្នកជាប់ពន្ធនឹងទទួលបានលិខិតជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញដែលមានទឹកប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ (ដូចមានក្នុងគំរូលិខិត (៦))។

ក្រោយពីទទួលបានលិខិតជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធអាចឯកភាពបង់តាមការកំណត់ពន្ធឡើងវិញ ឬតវ៉ាចំពោះការកំណត់ពន្ធនោះ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធឡើងវិញ បើសិនជាពុំបានឆ្លើយតបក្នុងរយៈពេល៣០ថ្ងៃ[5]។

### ក- ករណីអ្នកជាប់ពន្ធឯកភាពតាមការកំណត់ពន្ធឡើងវិញ

អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានកំណត់ឡើងវិញក្នុងរយៈពេល ៣០ថ្ងៃ ក្រោយទទួលបានលិខិតជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញនៅតាមបណ្ដាធនាគារដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ ឬតាមរយៈប្រព័ន្ធ e-Payment របស់អគ្គនាយកដ្ឋានពន្ធដារ។

[5] មាត្រា១១៨ នៃច្បាប់ស្ដីពីសារពើពន្ធ

### ខ- ករណីអ្នកជាប់ពន្ធជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ

ក្នុងករណីជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធមានសិទ្ធិដាក់ពាក្យបណ្ដឹងតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារ[6]។ លិខិតតវ៉ានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញ។

លិខិតតវ៉ារបស់អ្នកជាប់ពន្ធត្រូវមាននិទ្ទេសដូចខាងក្រោម÷

- លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកជាប់ពន្ធដែលធ្វើលិខិតតវ៉ា
- សេចក្ដីយោងទៅនឹងការកំណត់ពន្ធឡើងវិញដែលជាកម្មវត្ថុនៃលិខិតតវ៉ា
- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃលិខិតតវ៉ា
- ហេតុផលនៃការតវ៉ា
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬ តំណាងស្របច្បាប់ របស់អ្នកជាប់ពន្ធ។

ក្រោយដាក់លិខិតតវ៉ា អ្នកជាប់ពន្ធនឹងត្រូវបានអញ្ជើញមកពិនិត្យ និងដោះស្រាយ ដោយត្រូវបង្ហាញភ័ស្ដុតាងបន្ថែមដល់សវនករពន្ធដារ ដើម្បីជាមូលដ្ឋានសម្រាប់ដោះបន្ទុកការកំណត់ពន្ធឡើងវិញ។ រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្ដីសម្រេចជាថ្មីក្នុងរយៈពេល ៦០ ថ្ងៃ ក្រោយពីថ្ងៃបានទទួលលិខិតតវ៉ា ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវទាំងស្រុង ឬចំណែកណាមួយនៃការកំណត់ពន្ធ ដែលអ្នកជាប់ពន្ធតវ៉ា។

ប្រសិនបើមិនយល់ស្របលើសេចក្ដីសម្រេចថ្មីរបស់រដ្ឋបាលសារពើពន្ធទេនោះ អ្នកជាប់ពន្ធអាចដាក់លិខិតតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ។

[6] មាត្រា ១២០ នៃច្បាប់ស្ដីពីសារពើពន្ធ

ប្រសិនបើមិនយល់ស្របលើសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីទទួលបានលិខិតជូនដំណឹងស្តីពីការសម្រេចនោះ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានសវនកម្មសហគ្រាស
លេខ អពដ.នសសល-

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១

គំរូលិខិត (៥)

**លិខិតជូនដំណឹង**
**ស្តីពីការកំណត់ពន្ធឡើងវិញ**

**ជម្រាបជូន លោក~លោកស្រី នាយកក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុន :
ជាអក្សរឡាតាំង :
លេខអត្តសញ្ញាណកម្ម : ចុះបញ្ជីនៅ ៖ សាខាពន្ធដារខេត្តសៀមរាប
សកម្មភាពអាជីវកម្ម :
អាសយដ្ឋាន :

ខ្ញុំសូមជម្រាបជូន លោក-លោកស្រីថាសហគ្រាសរបស់លោក-លោកស្រីត្រូវបានធ្វើ**សវនកម្មពេញលេញ**លើរាល់ប្រតិបត្តិការដែលកើតមានក្នុងការិយបរិច្ឆេទ **ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២០។**

ដោយអនុលោមតាមមាត្រា១១៦ មាត្រា១១៧ និងមាត្រា១១៩ នៃច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានសវនកម្មសហគ្រាសសូមធ្វើការកែប្រែ ទិន្នន័យដែលជាមូលដ្ឋានសម្រាប់គណនាប្រាក់ពន្ធ-អាករនិងតម្រូវឱ្យលោក-លោកស្រីបង់បន្ថែមនូវប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដូចខាងក្រោម៖

| ការិយបរិច្ឆេទ | ប្រាក់ពន្ធ | ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|
| 2016-2017-2018-2019-2020 | | | | |

**ព័ត៌មានលម្អិតស្តីពីប្រភេទពន្ធនិងទឹកប្រាក់ពន្ធ/INFORMATION OF TAX TYPES AND AMOUNT DETAIL**

| ល.រ | ខែឆ្នាំ | ប្រភេទពន្ធ | ទឹកប្រាក់ពន្ធ | ប្រាក់ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|---|---|
| ១ | 01/2016-12/2016 | ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ | | | | |
| ២ | 01/2017-12/2017 | ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ | | | | |
| ៣ | 01/2018-12/2018 | ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ | | | | |
| ៤ | 01/2019-12/2019 | ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ | | | | |
| ៥ | 01/2020-12/2020 | ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ | | | | |

លោក-លោកស្រីមានរយៈពេល **៣០ថ្ងៃ** ក្រោយកាលបរិច្ឆេទនៃការប្រគល់លិខិតជូនដំណឹងនេះ សម្រាប់ឆ្លើយតបមកអគ្គនាយកដ្ឋានពន្ធដារវិញ នូវយោបល់ដែលអាចជាការយល់ព្រមឬជាការបដិសេធចំណែកណាមួយ ឬទាំងស្រុងចំពោះការកំណត់ពន្ធឡើងវិញនេះ ដោយត្រូវមានភ្ជាប់ជាមួយឯកសារបញ្ជាក់ជាភស្តុតាងផង។ ការមិនបានឆ្លើយតបក្នុងរយៈពេលនេះ ចាត់ទុកថាលោក-លោកស្រីបានយល់ព្រមតាមរដ្ឋបាលសារពើពន្ធ។

ក្នុងករណីលោក-លោកស្រីមិនបានបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានកំណត់ខាងលើនេះលោក-លោកស្រីអាចនឹងត្រូវទទួលរងនូវទោសទណ្ឌដទៃទៀត ដូចមានចែងក្នុងមាត្រា១៣០ មាត្រា១៣១ និងមាត្រា១៣២ នៃច្បាប់ស្តីពីសារពើពន្ធ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

**ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស**

P00000-2000-2000

**សវនករពន្ធដារ៖**

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ (+855) 23 886 715 ទូរសារ: (+855)23 886 715, Email: dea@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានសវនកម្មសហគ្រាស
លេខ អពដ.នសស

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១

គំរូលិខិត (៦)

**លិខិតជូនដំណឹង**
**ស្តីពីការកំណត់ពន្ធឡើងវិញ**

**ជម្រាបជូន លោក~លោកស្រី នាយកក្រុមហ៊ុន**

ឈ្មោះក្រុមហ៊ុន ៖
ជាអក្សរឡាតាំង ៖
លេខអត្តសញ្ញាណកម្ម ៖ ចុះបញ្ជីនៅ ៖ សាខាពន្ធដារខណ្ឌទួលគោក
សកម្មភាពអាជីវកម្ម ៖
អាសយដ្ឋាន ៖

ខ្ញុំសូមជម្រាបជូន លោក-លោកស្រីថាសហគ្រាសរបស់លោក-លោកស្រីត្រូវបានធ្វើ**សវនកម្មពេញលេញ**លើរាល់ប្រតិបត្តិការដែលកើតមានក្នុងការិយបរិច្ឆេទ **ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៨ ដល់ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២១។**

ដោយអនុលោមតាមមាត្រា១១៦ មាត្រា១១៧ និងមាត្រា១១៩ នៃច្បាប់ស្តីពីសារពើពន្ធ នាយកដ្ឋានសវនកម្មសហគ្រាសសូមធ្វើការកែប្រែ ទិន្នន័យដែលជាមូលដ្ឋានសម្រាប់គណនាប្រាក់ពន្ធ-អាករនិងតម្រូវឱ្យលោក-លោកស្រីបង់បន្ថែមនូវប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដូចខាងក្រោម៖

| ការិយបរិច្ឆេទ | ប្រាក់ពន្ធ | ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|
| 2019-2020-2021 | 22,480,960 ៛ | 8,992,384 ៛ | 4,424,987 ៛ | 35,898,331 ៛ |

**ព័ត៌មានលម្អិតស្តីពីប្រភេទពន្ធនិងទឹកប្រាក់ពន្ធ/INFORMATION OF TAX TYPES AND AMOUNT DETAIL**

| ល.រ | ខែឆ្នាំ | ប្រភេទពន្ធ | ទឹកប្រាក់ពន្ធ | ប្រាក់ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|---|---|
| ១ | 01/2019-12/2019 | | 9,219,960 ៛ | 3,687,984 ៛ | 3,042,587 ៛ | 15,950,531 ៛ |
| ២ | 01/2020-12/2020 | | 9,216,000 ៛ | 3,686,400 ៛ | 1,382,400 ៛ | 14,284,800 ៛ |
| ៣ | 01/2021-06/2021 | | 4,045,000 ៛ | 1,618,000 ៛ | | 5,663,000 ៛ |

លោក-លោកស្រីមានរយៈពេល **៣០ថ្ងៃ** ក្រោយកាលបរិច្ឆេទនៃការប្រគល់លិខិតជូនដំណឹងនេះ សម្រាប់ឆ្លើយតបមកអគ្គនាយកដ្ឋានពន្ធដារវិញ នូវយោបល់ដែលអាចជាការយល់ព្រមឬជាការបដិសេធចំណែកណាមួយ ឬទាំងស្រុងចំពោះការកំណត់ពន្ធឡើងវិញនេះ ដោយត្រូវមានភ្ជាប់ជាមួយឯកសារបញ្ជាក់ជាភស្តុតាងផង។ ការមិនបានឆ្លើយតបក្នុងរយៈពេលនេះ ចាត់ទុកថាលោក-លោកស្រីបានយល់ព្រមតាមរដ្ឋបាលសារពើពន្ធ។

ក្នុងករណីលោក-លោកស្រីមិនបានបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានកំណត់ខាងលើនេះលោក-លោកស្រីអាចនឹងត្រូវទទួលរងនូវទោសទណ្ឌដទៃទៀត ដូចមានចែងក្នុងមាត្រា១៣០ មាត្រា១៣១ និងមាត្រា១៣២ នៃច្បាប់ស្តីពីសារពើពន្ធ។

សូមលោក-លោកស្រីនាយកក្រុមហ៊ុន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

**ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស**

P00000-2000-2000

**សវនករពន្ធដារ៖**

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 715, ទូរសារ: (+855) 23 886 715, Email: dea@tax.gov.kh, Website: www.tax.gov.kh

## ចម្ងល់ផ្សេងៗ និងការពិគ្រោះយោបល់

ករណីលោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសមានចម្ងល់ផ្សេងៗ សូមទំនាក់ទំនងតាមរយៈ Call Center របស់អគ្គនាយកដ្ឋានពន្ធដារលេខ **១២៧៧** ដោយឥតគិតថ្លៃ ឬផ្ញើសារមកកាន់ GDT Live Chat ឬសារអេឡិចត្រូនិក info@tax.gov.kh។ លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសក៏អាចមកធ្វើការទំនាក់ទំនងដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋានខាងក្រោម៖

**លេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្សី (១១០) និងមហាវិថីម៉ៅសេទុង (២៤៥)**

**សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ**

**ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨៦ ៧០៨**